**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៥៧ សហវ

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០០៣

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**ការបង្កើតវត្ថុទេយ្យបុរប្រទាន**

**នៅលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម**

**- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**- លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២. ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១៧/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពី វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស /រកម /១២០២ / ០២០ ចុះថ្ងៃទី៣០ ខែធ្នូឆ្នាំ២០០២ ។

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៣

-បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទ បញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញសារាចរណែនាំលេខ ០០៣ ស.ហ.វ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីវត្ថុទេយ្យបុរប្រទាន

-បានឃើញប្រកាសលេខ១២៩ ប្រក.សហវ ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ១៩៩៧ ស្ដីពីការកំនត់ទឹកប្រាក់រដ្ឋទេយ្យបុរេប្រទានជំពូក១១ សំរាប់ទូទាត់ចំណាយចាំបាច់ ទៅលើដំណើរការរដ្ឋបាលសំភារៈ និងជួសជុលតូច ។

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

**សំរេច**

**ប្រការ១** : ត្រូវបានបង្កើតរដ្ឋទេយ្យបុរេប្រទាន នៅលេខាធិការដ្ឋាន ឧត្ដមក្រុមប្រឹក្សា នៃអង្គចៅក្រម ដែលត្រូវប្រើប្រាស់ថវិកា ជំពូក១១ ដើម្បី ទូទាត់ចំណាយទាំងឡាយណាដែលមានចែងក្នុងមាត្រា៦៤ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ។ ចំនួន ទឹកប្រាក់ជាអតិបរិមា នៃការចំណាយដែលអនុញ្ញាត អោយរដ្ឋទេយ្យករបុរេប្រទាន ធ្វើការទូទាត់ ត្រូវ កំណត់កំរិតក្រោម ៥០០.០០០,០០ (ប្រាំរយពាន់រៀលគត់) តាមចំណាត់ថ្នាក់ចំណាយនីមួយៗ ដូចមានចែងក្នុងតារាង ឧបសម្ព័ន្ធ ភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

**ប្រការ២** : ចំនួនទឹកប្រាក់ នៃរដ្ឋទេយ្យបុរេប្រទាន ជំពូក១១ សំរាប់មួយជុំនៃឆ្នាំ ត្រូវបានកំណត់ត្រឹម ចំនួន ១៥.៦០០.០០០,០០ (ដប់ប្រាំលានប្រាំមួយរយពាន់រៀលគត់) សំរាប់ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ។

**ប្រការ៣** : សេចក្ដីសំរេចទាំងឡាយណាដែល មានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍

**ប្រការ៤** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង លេខាធិការដ្ឋាន នៃឧត្ដមក្រុមប្រឹក្សា នៃអង្គចៅក្រម ត្រូវទទួលបន្ទុក អនុវត្តតាម ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

លេខាធិការ
នៃឧត្ដមក្រុមប្រឹក្សា នៃអង្គចៅក្រម

ឡៀប មុន

<u>ចម្លងជូន</u>

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ទីស្ដីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការ៤
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ